00876928

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / 01 / 2013
ម៉ោង (Time/Heure) : 15:16
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

002/19-09-2007-ECCC/TC
E1/151

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ ទី ១១ ខែ ធ្នូ ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៣៨

រៀបចំដោយ: ឌុច ផារី និង Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធួ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Roger PHILLIPS, |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វ៉េង ហ៊ត់, លោក Tarik ABDULHAK , លោក Vincent DE WILDE D'ESTMAEL |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន, អៀង សារី (ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZI |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ អង្គ, លោកស្រី ទី ស្រីនណា, លោក ហុង គឹមសួន, លោក ឡោ ជុនធី, , លោក សំ សុគង់, លោក គឹម ម៉េងឃី, លោកស្រី Isabelle DURAND, លោកស្រី Martine JACQUIN |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ហ៊ុន ឈុនលី (TCCP-427), លោក ខាំ ផាន់ ហៅ ផាន វ៉ាន (TCW-307) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា Laura GRETZ លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី) |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.១០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖ ១១.០០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង និង ០០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី អៀង សារី សុំឱ្យមានសវនាការជាសាធារណៈ | អង្គជំនុំជម្រះ | ៩.០៥ | ៩.០៧ |
| ការបន្តស្តាប់សក្ខីកម្មរបស់សាក្សី ហ៊ុន ឈុនលី TCW-247 | មេធាវីការពារក្តី អៀង សារី | ៩.១២ | ១០.៣៩ |
| ការស្តាប់សក្ខីកម្មរបស់សាក្សី ខាំ ផាន់ ហៅ ផាន វ៉ាន (TCW-307) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១១.០២<br>១១.១១<br>១៣.៤៤<br>១៥.០២ | ១១.១១<br>១១.៥៩<br>១៤.៣៩<br>១៦.០៦ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួម | ជនជាប់ចោទ នួន ជា | ១១.៥៩ | ១២.០៤ |

| សវនាការដោយផ្ទាល់ | អង្គជំនុំជម្រះ | | |
|---|---|---|---|
| សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី អៀង សារី ទាក់ទងនឹងការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 | អង្គជំនុំជម្រះ | ១៣.៣២ | ១៣.៤៣ |
| ដីកាបង្គាប់ផ្ទាល់មាត់ឱ្យនាំជនជាប់ចោទមកកាន់បន្ទប់សវនាការនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ | អង្គជំនុំជម្រះ | ១៦.០៧ | ១៦.០៨ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី អៀង សារី សុំឱ្យមានសវនាការជាសាធារណៈ:**

មេធាវីការពារក្តី អៀង សារី ស្នើសុំឱ្យមានសវនាការជាសាធារណៈដើម្បីលើកឡើងនូវសារណារបស់ខ្លួនដែលថាជនជាប់ចោទ អៀង សារី និងគ្រូពេទ្យដែលព្យាបាលគាត់នៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការគួរតែត្រូវបានអនុញ្ញាតិឱ្យថតនូវខ្សែអាត់វីដេអូ ។ អង្គជំនុំជម្រះបានសម្រេចថា សវនាការដើម្បីដេញដោលលើបញ្ហានេះគឺមិនមានភាពចាំបាច់នោះទេ ព្រោះអង្គជំនុំជម្រះបានស្នើឱ្យភាគីដាក់នូវសារណាជាលាយលក្ខអក្សរណ៍ ដោយលើកឡើងពីប្រភពនៃឯកសារលើបញ្ហានេះរួចហើយ ។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ មិនបានចង្អុលបង្ហាញនូវការណែនាំណាមួយជាក់លាក់ទាក់ទងនឹងបញ្ហានេះនោះទេ ។ ហេតុដូច្នេះ អង្គជំនុំជម្រះបានរំឭកដល់មេធាវីការពារក្តី អៀង សារី ថា មេធាវីត្រូវស្នើសុំការអនុញ្ញាតិពីអង្គជំនុំជម្រះជាមុន ក្នុងការបន្តនូវការថតខ្សែអាត់វីដេអូលើរូបលោក អៀង សារី ដោយអនុលោមតាមវិធាន ៩២ និងសម្រេចបដិសេធលើសំណើរបស់មេធាវីការពារក្តី ។

**ការបន្តស្តាប់សក្ខីកម្មរបស់សាក្សី ហ៊ុន ឈុនលី (TCW-247)**

មេធាវីការពារក្តី អៀង សារី បន្ត និងបញ្ចប់នូវការតាំងសំណួរដល់សាក្សី ហ៊ុន ឈុនលី (TCW-247) ។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ សម្រាប់ពេលរសៀល។ អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំ និងបានកត់សម្គាល់ផងដែរថា ការពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា គឺត្រូវធ្វើឡើងតាមការយល់ឃើញរបស់គ្រូពេទ្យដែលប្រចាំការនៅ អ.វ.ត.ក មិន មែនធ្វើឡើងតាមការយល់ឃើញរបស់មេធាវីការពារក្តីនោះទេ ។

**ការស្តាប់សក្ខីកម្មរបស់សាក្សី ខាំ ផាន់ ហៅ ផាន វ៉ាន** (TCW-307)

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនដល់សាក្សី ខាំ ផាន់ ហៅ ផាន វ៉ាន (TCW-307) ។ បន្ទាប់មកការតាំងសំណួរបន្តដោយសហព្រះរាជអាជ្ញា ។

**សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី អៀង សារី ទាក់ទងនឹងការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី** TCCP-1

អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលជំទាស់ទៅនឹងការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 តាមរយៈប្រព័ន្ធសោទស្សន៍ ពីប្រទេសបារាំង ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|
| E3/33 51 | D313/1. 2.8 | 00678744-00678942 00369669-00369820 00700301-00700309 | សៀវភៅនិពន្ធដោយលោក HUN Chunly មានចំណងជើងថា "ជីវិតគ្រូពេទ្យម្នាក់ក្នុងរបបខ្មែរក្រហម"<br>Book by HUN Chunly entitled "The Life of a Physician under the Khmer Rouge Regime"<br>Livre de HUN Chunly intitulé "The Life of a Physician under the Khmer Rouge Regime" | P | 00678756-00678757, 00678751, 00678941-00678942, 00678900 | 00369681, 00369675, 00369820, 00369787 | |
| E3/58 | D125/ 160 | 00239934-00239940 00250086-00250092 00283912-00283918 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន វ៉ាន់ PHAN Van, Alias KHĂM Phăn<br>Written Record of Interview of PHAN Van, Alias KHĂM Phăn<br>Procès verbal d'audition de PHAN Van, Alias KHĂM Phăn | P | 00239935, 00239937 | 00250087, 00250088, 00250089 | 00283913, 00283915 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/57 | D200/4 | 00287700-00287709 00290503-00290511 00353098-00353108 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី KHAM Phăn ខាំ ផាន់<br>[Corrected 1] Written Record of interview of KHAM Phăn ខាំ ផាន់<br>Procès verbal d'audition de témoin KHAM Phăn ខាំ ផាន់ | P | 00287701-00287702, 00287704-00287706 | 00290505. 00290506-508 | 00353099, 00353100, 00353104 |
| E3/3974 | D22/36 | 00323540-00323556 00856467-00856481 00279622-00279632 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី AFFONCO Denise<br>Civil party application of Ms. Affonco Denise<br>Demande de constitution de partie civile de Mme. Affonco Denise | P | | | |
| E3/3975 | D22/36.2 | 00279633-00279641 | Annexe 2: Livret de famille et photos avec un atlas du Cambodge | P | | | |
| E3/3976 | D199/15 | 00349104-00349122 00346929-00346937 00342178-00342185 | កំណត់ហេតុនៃការស្តាប់ចម្លើយ AFFONCO Denise<br>Written Record of Interview of AFFONCO Denise<br>Procès verbal d'audition de AFFONCO Denise | P | | | |
| E3/1645 | D175/3.31 | 00230386-00230394 00809627-00809639 00809998-00810017 | ឈ្មោះអ្នកចូលថ្ងៃ២៣.១១.៧៧<br>Name who entered on 23.11.77<br>Nom des prisonniers arrivés le 23 novembre 1977 | P | | | |
| E3/2597 | D175/3.78 | 00231237-00231331 00820641-00820653 00800646-00800659 | ការទាក់ទងបងយ៉ា-ចម្លើយ សូ គឹមអាន ហៅ មុី អនុលេខាតំបន់ ១០៥<br>[Partial T.] Relate to Brother Ya: Confession of So Kim An deputy secretary Region 105<br>[Partial T.] Aveux de So Kim An, secrétaire adjoint de la région 105, lié à Bong Ya | P | | | |
| E3/1191 | D366/7.1.778 | 00021530-00021530 00539058-00539058 00531062-00531062 | ជូនមិត្ត ឌឿន ជាទីស្នេហានិងរលឹក<br>To beloved and missed Comrade Doeun<br>To beloved and missed Comrade Doeun | P | 00021530 | 00539058 | 00531062 |
| E3/1192 | D366/7.1.779 | 00021529-00021529 00508560-00508560 00499961-00499961 | ទូរលេខ ២ ជូនបង នួន<br>Telegram No. 2 : To Dearest Brother Nuon<br>Télégramme 2: Cher frère Nuon | P | 00021529 | 00508560 | 00499961 |

<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>

- **សេចក្តីសម្រេចផ្ទាល់មាត់ទាក់ទងនឹងការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1៖**

នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានទទួលអនុស្សរណៈមួយពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីមានរហស្សនាម TCCP-1 ដែលមានអាយុ ៦៨ ឆ្នាំ បានស្នើសុំផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ និងបានបញ្ជាក់ថា (១) គាត់បានសម្តែង "នូវការព្រួយបារម្ភយ៉ាងខ្លាំងអំពីការធ្វើដំណើរមកទីក្រុងភ្នំពេញ ដើម្បីផ្តល់ចម្លើយដោយផ្ទាល់" (២) គាត់ "បន្តរងការឈឺចាប់ដោយសារការចងចាំនូវបទពិសោធន៍យ៉ាងជូរចត់ ចំពោះព្រឹត្តិការណ៍នានាដែលគាត់បានជួបប្រទះមុនពេលគាត់ចាកចេញពីប្រទេសកម្ពុជា"(៣)គាត់បានបាត់បង់មនុស្សគ្រប់គ្នាដែលគាត់បានស្គាល់នៅប្រទេសកម្ពុជា និង (៤) ស្វាមីរបស់គាត់គាត់មិនអាចធ្វើដំណើរជាមួយគាត់មកប្រទេសកម្ពុជាដើម្បីជួយគាំទ្រដល់គាត់បានទេ (ឯកសារលេខ E236/1/1)។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដោយអនុញ្ញាតឱ្យគាត់ផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង និងបានកំណត់កាលបរិច្ឆេទសម្រាប់ការផ្តល់សក្ខីកម្មរបស់គាត់ពីថ្ងៃទី ១២ ដល់ទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (ឯកសារលេខ E236/1/1/1)។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-1 នេះ មិនមែនជាអ្នកជំនាញទេ ហើយនឹងទំនងជាមិនមានឯកសារត្រូវបង្ហាញច្រើនទេពាក់ព័ន្ធចំពោះគាត់។ ហេតុដូច្នេះ គាត់អាចផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍បាន។ អង្គជំនុំជម្រះក៏បានកត់សម្គាល់បន្ថែមទៀតថា ដោយសារដើមបណ្តឹងរដ្ឋប្បណីរូបនេះ មានភាពទន់ខ្សោយផ្នែកផ្លូវចិត្ត និងផ្លូវកាយនោះ ទើបតម្រូវឱ្យមានការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ដូចនេះ។ នាពេលនោះ ភាគីមិនបានទទួលដំណឹងពីសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ហើយភាគីក៏មិនបានប្តឹងជំទាស់អ្វីដែរ។

ពេលនេះ មេធាវីការពារក្តី អៀង សារី បានស្នើសុំដល់អង្គជំនុំជម្រះឱ្យបង្ហាញភស្តុតាងបន្ថែមទៀតដើម្បីគាំទ្រសេចក្តីសម្រេចរបស់ខ្លួន ដោយសារ "អង្គជំនុំជម្រះសាលាដំបូងមិនបានបង្ហាញ" ថា សំណើសុំរបស់ TCCP-1 គឺមានហេតុផលសមស្របអាចទទួលយកបាន។ មេធាវីការពារក្តី អៀង សារី បានស្នើសុំបន្ថែមទៀតថា TCCP-1 ត្រូវមកផ្តល់សក្ខីកម្មដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ (ឯកសារលេខ E236/1/1/2 ("សំណើសុំ" កថាខណ្ឌ ១៧)។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការអនុញ្ញាតឱ្យផ្តល់ភស្តុតាងតាមរយៈប្រព័ន្ធសោតទស្សន៍បាន ប្រសិនបើចាំបាច់ត្រូវធ្វើដូច្នេះ ដរាបណាវិធានការទាំងនេះមិន "ប៉ះពាល់ធ្ងន់ធ្ងរ ឬ រំលោភទៅលើសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ"។ សូមមើល សេចក្តីសម្រេចរបស់តុលាការ ICC នៅក្នុង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bemba* ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២,

កថាខណ្ឌ ៥; *សូមមើលផងដែរ* វិធាន ២៦(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

មេធាវីការពារក្តីបានលើកឡើងថា ការអនុញ្ញាតឱ្យផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 តាមរយៈប្រព័ន្ធសោតទស្សន៍នឹង "ប៉ះពាល់" ដល់សិទ្ធិរបស់ជនជាប់ចោទ ពីព្រោះថា "វាមានហេតុផលសមស្របក្នុងការសន្មតថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 នេះ គឺជាសក្ខីកម្មដាក់បន្ទុក" ក្នុងអំឡុងពេលជំនុំជម្រះជនជាប់ចោទ អៀង សារី នៅក្នុងឆ្នាំ ១៩៧៩ (សំណើសុំ, កថាខណ្ឌ ១៥)។ មេធាវីការពារក្តីបានជំទាស់ដោយលើកឡើងថា ការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ មិនមែនជាការចាំបាច់ដើម្បីបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទទេ (សំណើសុំ, កថាខណ្ឌ ១៣)។ ទោះបីជនជាប់ចោទរក្សាសិទ្ធិជំទាស់នឹងសក្ខីកម្មសាក្សីដែលបានផ្តល់ដោយគ្មានវត្តមានរបស់គាត់នៅពេលដែលការផ្តល់សក្ខីកម្មនោះ "ប៉ះពាល់ដោយផ្ទាល់ក្តី ដោយមិនផ្ទាល់ក្តី ឬ ការប្រព្រឹត្ត ឬ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ដល់ជនជាប់ចោទនៅក្នុងដីកាដំណោះស្រាយ" ក៏ដោយ ក៏ជនជាប់ចោទ អៀង សារី ធ្លាប់បានលះបង់សិទ្ធិក្នុងការចូលរួមស្តាប់សក្ខីកម្មនៅក្នុងបន្ទប់សវនាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 រួចហើយ (ឯកសារលេខ E237) ជាពិសេសនៅពេលដែល អៀង សារី និង មេធាវីរបស់គាត់បានពិនិត្យមើលឯកសារនានា ដែលបានពិពណ៌នាច្បាស់លាស់ពីបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ រួមទាំងការបាត់បង់ស្វាមី កូនស្រី និង សាច់ញាតិដទៃទៀតរបស់គាត់ជាច្រើននាក់ផងដែរនោះ (ឯកសារលេខ D22/36, D22/36.2, D199/15)។ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ជនជាប់ចោទ អៀង សារី មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការនោះ លិខិតលះបង់សិទ្ធិក៏ត្រូវបានដកចេញដែរ (ឯកសារលេខ E237/2)។ ហើយនាពេលនេះ មេធាវីការពារក្តី អៀង សារី បានលើកឡើងថា ការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍មិនបានអនុញ្ញាត ឱ្យលោក អៀង សារី ឬមេធាវីរបស់គាត់ វាយតម្លៃយ៉ាងពេញលេញចំពោះការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានទេ (សំណើសុំ, កថាខណ្ឌ ១៦)។ ដូចដែលការិយាល័យសហព្រះរាជអាជ្ញាបានកត់សម្គាល់រួចមកហើយគឺថា អំណះអំណាងនេះផ្ទុយពីវិធានដែលបានបង្កើតឡើងនៅកំរិតអន្តរជាតិដោយតុលាការ ICTY ដែលបានសម្រេចថា សិទ្ធរបស់ជនជាប់ចោទមិនប៉ះពាល់ដោយសារតែអវត្តមានរបស់សាក្សីនៅពេលការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ត្រូវបានអនុញ្ញាតនោះឡើយ។

មេធាវីការពារក្តីក៏បានលើកឡើងបន្ថែមទៀតថា មិនមានភស្តុតាងគាំទ្រដល់ភាពទន់ខ្សោយផ្នែកផ្លូវកាយ និងផ្លូវចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 ទេ (សំណើសុំ, កថាខណ្ឌ ១១)។ អង្គជំនុំជម្រះកត់សម្គាល់ថា ការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ត្រូវបានធ្វើយុត្តិកម្មយ៉ាងពេញលេញដើម្បី "ការពារសុខុមាល

ភាពផ្លូវចិត្ត និងសេចក្តីថ្លៃថ្នូររបស់សាក្សី ដែលស្ថិតក្រោមបញ្ញត្តិជាសារវ័ន្តនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌”។ *សូមមើល* សេចក្តីសម្រេចរបស់តុលាការ ICC នៅក្នុងរឿងក្តី Lubanga ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០, កថាខណ្ឌ ១៥ ដល់កថាខណ្ឌ ១៦។ បន្ថែមទៅលើការប្រាស្រ័យទាក់ទងរវាងដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 និងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ TCCP-1 បានបញ្ជាក់ច្បាស់លាស់ហើយថា គាត់បានទទួលរងព្យសនកម្មផ្លូវកាយ សម្ភារៈ និងផ្លូវចិត្ត ដោយផ្អែកយ៉ាងហោចណាស់ លើឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០១ នេះដែរ (វិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង)។ ការពិត ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយការិយា- ល័យសហចៅក្រមស៊ើបអង្កេត ដែលមេធាវីការពារក្តី អៀង សារី មិនបានប្តឹងឧទ្ធរណ៍នេះ ក៏បានគាំទ្រដល់ការលើកឡើងខាងលើនេះដែរ។ លើសពីនេះទៀត អង្គជំនុំជម្រះទើបបានទទួលលិខិតពេទ្យមួយច្បាប់ដែល បានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីខាងលើនេះមិនអាចធ្វើដំណើមកប្រទេសកម្ពុជាបានទេ ដោយសារលក្ខខណ្ឌសុខភាពរបស់គាត់ មិនអនុញ្ញាតឱ្យគាត់ធ្វើដំណើមកបាន។

សម្រាប់សំអាងហេតុទាំងឡាយខាងលើ អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលសុំកោះហៅដើមបណ្តឹងរដ្ឋប្បវេណីមានរហស្សនាម TCCP-1 មកផ្តល់សក្ខីកម្មនៅប្រទេសកម្ពុជា។

- **សេចក្តីសម្រេចលើសំណើសុំថតខ្សែអាត់វីដេអូលើរូបលោក អៀង សារី៖**

  អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលបានស្នើសុំឱ្យមានសវនាការជាធារណៈដើម្បីបង្ហាញនូវអំណះអំណាងរបស់ខ្លួន ដែលថាលោក អៀ សារី និងគ្រូពេទ្យដែលព្យាបាលគាត់នៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ គួរតែត្រូវបានអនុញ្ញាតិឱ្យថតខ្សែអាត់វីដេអូ។

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យជនជាប់ចោទ នួន ជា (១២.០០) ចូលរួមដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួន។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូន សាក្សី ហ៊ុន ឈុនលី TCW-247 និង ខាំ ផាន់ ហៅ ផាន វ៉ាន (TCW-307) ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំសាក្សី ខាំ ផាន់ ត្រឡប់មកកាន់សាលសវនាការវិញនៅព្រឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ខៀវ សំផន និង អៀង សារី ត្រឡប់ទៅ

កាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃទ ០៧ ខែ ធ្នូ ឆ្នាំ ២០១២ (ចំពោះជនជាប់ចោទ អៀង សារី ត្រូវនាំមកកាន់បន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) ។

| <u>**កាលបរិច្ឆេទបន្តសវនាការ៖**</u> |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២

ក្រឡាបញ្ជី[illegible]ក្រឡាបញ្ជី

ឌុច ឆ[illegible] R[illegible] [illegible]LLIPS